ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ចាម

សំណុំរឿងព្រហ្មទណ្ឌ
លេខ៩៩ /០៨.០២.២០១៨

សាលក្រម
លេខ ៥៩២ "យ" ចុះថ្ងៃទី២១
ខែសីហា ឆ្នាំ២០១៩

# សាលក្រម

## តាមនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកំពង់ចាម

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩ ដោយមានសមាសភាពដូចតទៅ:

ចៅក្រមជំនុំជម្រះ

លោក [redacted] ជាចៅក្រមសាលាដំបូងខេត្តកំពង់ចាម

តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកំពង់ចាម

ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ចាម

មេធាវីការពារ

លោក [redacted] (ការពារឱ្យជនជាប់ចោទឈ្មោះ [redacted] វៃ និងឈ្មោះ [redacted] ម៉ាប់)

លោក [redacted] សុគង់ (ការពារឱ្យជនជាប់ចោទឈ្មោះ [redacted] ចន្ទី)

លោក [redacted] ខូស្សាហ៏ (ជាមេធាវីតំណាងអាណត្តិឱ្យដើមបណ្តឹងរដ្ឋប្បវេណីទាំង១៣០គ្រួសារ)

-ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៩៩ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៨ដែលមានជនជាប់ចោទ៖

១/ឈ្មោះ [redacted] ចន្ទី ហៅ [redacted] ចាន់ឌី ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ មុខរបរនាយកអង្គការគ្រួសាររ៉ុងរឿងអភិវឌ្ឍន៍កម្ពុជា កើតនៅភូមិស្វាយព្រៃ ឃុំសណ្តែក ស្រុកបាធាយ ខេត្តកំពង់ចាម ទីលំនៅសព្វថ្ងៃភូមិ [redacted] ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" នៅលីវ ទោសពីមុនគ្មាន (គេចខ្លួន)។

២/ឈ្មោះ [redacted] វៃ ភេទប្រុស អាយុ៥២ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ កើតនៅភូមិស្វាយព្រៃ ឃុំសណ្តែក ស្រុកបាធាយ ខេត្តកំពង់ចាម ទីលំនៅសព្វថ្ងៃភូមិ [redacted] ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ប្រពន្ធឈ្មោះ [redacted] "រ" មានកូន០១នាក់ ទោសពីមុនគ្មាន (ក្រៅឃុំ)

៣/ឈ្មោះ [redacted] ម៉ាប់ ភេទស្រី អាយុ២៩ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ កើតនៅភូមិស្វាយព្រៃ ឃុំសណ្តែក ស្រុកបាធាយ ខេត្តកំពង់ចាម ទីលំនៅសព្វថ្ងៃភូមិ [redacted]

Scanned with CamScanner

[redacted] ឪពុកឈ្មោះ[redacted] "រ" ម្តាយឈ្មោះ[redacted] "រ" ប្តីឈ្មោះ[redacted] "រ" កូនគ្មាន ទោសពីមុនគ្មាន (ក្រៅឃុំ)។

-ជាប់ចោទពីបទៈ *រំលោភលើទំនុកចិត្ត* ប្រព្រឹត្តនៅភូមិស្វាយព្រៃ ឃុំសណ្តែក ស្រុកបាធាយ ខេត្តកំពង់ចាម កាលពីអំឡុងឆ្នាំ២០១៤បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៣៩១ មាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ។

**ឯរឿងហេតុមានដូចតទៅ**

កាលពីអំឡុងឆ្នាំ២០១៤ នៅភូមិស្វាយព្រៃ ឃុំសណ្តែក ស្រុកបាធាយ ខេត្តកំពង់ចាម មានឈ្មោះ[redacted]ចន្ធនី ហៅ[redacted]ចាន់នី ភេទប្រុស អាយុ២៩ឆ្នាំ បានបើកអង្គការគ្រួសាររុងរឿងអភិវឌ្ឍន៍កម្ពុជា ទទួលប្រាក់បញ្ញើ និងផ្តល់ការប្រាក់៣% ដល់ប្រជាពលរដ្ឋចំនួន១៣០គ្រួសារដែលរស់នៅភូមិ ឃុំខាងលើ ដោយមានឈ្មោះ[redacted] វៃ ភេទប្រុស អាយុ៥១ឆ្នាំ និងឈ្មោះ[redacted] ម៉ាប់ ភេទស្រី អាយុ២៩ឆ្នាំ ជាអ្នកប្រមូលប្រាក់បញ្ញើពីប្រជាពលរដ្ឋឱ្យទៅអង្គការគ្រួសាររុងរឿងអភិវឌ្ឍន៍កម្ពុជា។ លុះដល់ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨ ឈ្មោះ[redacted]ចន្ធនី ឈ្មោះ[redacted] វៃ និងឈ្មោះ[redacted] ម៉ាប់ បានគេចវេសមិនទូទាត់ប្រាក់បញ្ញើ និងការប្រាក់ឱ្យប្រជាពលរដ្ឋចំនួន១៣០គ្រួសារវិញទេ។ ក្រោយពេលកើតហេតុប្រជាពលរដ្ឋទាំង១៣០គ្រួសារ បានប្តឹងទៅសមត្ថកិច្ចនគរបាលឱ្យជួយដោះស្រាយ។ ក្រោយពីទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋសមត្ថកិច្ចបានបើកការស៊ើបអង្កេត កសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងខេត្តកំពង់ចាម ចាត់ការតាមនីតិវិធីច្បាប់។

-បានឃើញរបាយការណ៍លេខ ៤៩ រ.ប.ក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៨ របស់អធិការនគរបាលស្រុកបាធាយ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ២៧១ ព.ស ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩។

-បានឃើញដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ៧៤៧ ចុះថ្ងៃទី០៥.០៧.២០១៩។

-បានឃើញសំណុំរឿងជំនុំជម្រះលេខ ៣៦៩ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ៤០៩ ចុះថ្ងៃទី០៧.០៧.២០១៩។

**<u>នាពេលសវនាការ</u>**

-ជនជាប់ចោទឈ្មោះ[redacted]*ចន្ធនី* (អវត្តមាន)

-ជនជាប់ចោទឈ្មោះ[redacted] *វៃ* បានឆ្លើយនាពេលសវនាការថាៈ កាលពីអំឡុងឆ្នាំ២០១៣ ឈ្មោះ[redacted] ចាន់នី ត្រូវជាក្មួយបង្កើតរបស់ខ្ញុំ បានមកដល់ផ្ទះខ្ញុំ ហើយនិយាយបញ្ចុះបញ្ចូលខ្ញុំឱ្យជួយទំនុកបំរុងក្នុងការបើកក្រុមហ៊ុនមីក្រូហិរញ្ញវត្ថុ ដែលមានឈ្មោះថា អង្គការគ្រួសាររុងរឿងអភិវឌ្ឍន៍កម្ពុជា មានទីតាំងនៅផ្ទះលេខ៧២$E_0E_1$ ភូមិថ្នល់បែក សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ ឈ្មោះ[redacted] ចាន់នី បាននិយាយប្រាប់ខ្លួនថា វាធ្លាប់មានបទពិសោធន៍ក្នុងការរកស៊ីចងការប្រាក់នៅអង្គការមរតក ហើយវារកចំណូលបានក្នុងមួយខែ ពី២.៧០០$ ទៅ៣.០០០$ បើពូមានចំណាប់អារម្មណ៍ចូលលុយរកស៊ីជាមួយខ្ញុំទៅ មានត្រឹមតែ៣.០០០$ ទៅ៤.០០០$ ក៏បានដែរ។ ដោយសារមានការជឿជាក់ ម្យ៉ាងទៀតវាជាក្មួយផងនោះ ទើបខ្លួនព្រមដាក់ទុនជាមួយវាទៅ ដោយដាក់ជាហ៊ុហៃរ ។ ពេលប្រជាពលរដ្ឋក្នុងភូមិឃើញអង្គការនេះដំណើរការល្អ ប្រជាពលរដ្ឋក៏មកសុំខ្ញុំ យកប្រាក់មកផ្ញើនៅអង្គការនេះដែរ។ ប្រជាពលរដ្ឋភាគច្រើនខ្ញុំជាអ្នកទទួលប្រាក់ពីពួកគាត់ ការប្រាក់ក្នុង១.០០០.០០០(មួយលាន)រៀលទូលបានចំនួន៣០.០០០(បីម៉ឺន)រៀលក្នុងមួយខែ។ លុយដែល

Scanned with CamScanner

ប្រជាពលរដ្ឋយកមកផ្ញើនៅខ្ញុំមានចំនួន១៨៦គ្រួសារ ដោយបានឱ្យការប្រាក់រាល់ខែ លុយដែលនៅសល់ខ្ញុំផ្ញើឱ្យទៅឈ្មោះ [redacted] ចាន់នី ដោយវេតាមទូមាស តាមវីង។ ខ្ញុំបានទទួលលុយពីប្រជាពលរដ្ឋមែន។ មូលហេតុដែលប្រជាពលរដ្ឋប្តឹង គ្មានលុយសង ព្រោះឈ្មោះ [redacted] ចាន់នី បានយកទៅអស់។ ខ្ញុំធ្វើការបានប្រាក់ខែពីឈ្មោះ [redacted] ចាន់នី ចំនួន៣០០(បីរយដុល្លា) ក្នុងមួយខែ ខ្ញុំគ្មានភាគហ៊ុនក្នុងអង្គការទេ។

-ជនជាប់ចោទឈ្មោះ [redacted] *ម៉ាប់* បានឆ្លើយនាពេលសវនាការថា: សព្វថ្ងៃនាងខ្ញុំមានផ្ទៃពោះ៧ខែ នាងខ្ញុំគ្មានមុខងារអ្វីនៅក្នុងអង្គការនេះទេ។ ទំនាក់ទំនងរវាងឪពុកនាងខ្ញុំ និងឈ្មោះ [redacted] ចាន់នី នាងខ្ញុំមិនបានដឹងច្បាស់ទេ គ្រាន់តែបានដឹងថា ឈ្មោះ [redacted] ចាន់នី មានបង្កើតអង្គការគ្រួសាររ៉ុងរឿងអភិវឌ្ឍន៍កម្ពុជា ហើយទទួលប្រាក់បញ្ញើពីប្រជាពលរដ្ឋ។ ពេលអង្គការនេះនៅដំណើរការ នៅពេលណាឪពុកនាងខ្ញុំមិននៅផ្ទះ ហើយមានប្រជាពលរដ្ឋយកប្រាក់មកផ្ញើ ឪពុកនាងខ្ញុំគាត់ធ្លាប់ឱ្យខ្ញុំទទួលប្រាក់ជំនួសម្តងម្កាល និងធ្លាប់វេប្រាក់ឱ្យទៅឈ្មោះ [redacted] ចាន់នី ម្តងម្កាលដែរ នៅពេលណាឪពុកខ្ញុំប្រើ។ រាល់ការបំពេញឯកសារ នាងខ្ញុំសរសេរបំពេញ ពេលប្រជាពលរដ្ឋយកលុយមកផ្ញើ ហើយឪពុកនាងខ្ញុំអត់នៅផ្ទះ។ នាងខ្ញុំគ្មានប្រាក់ខែ គ្រាន់តែជួយសរសេរឪពុក ក្រោឈ្មោះរបស់ឪពុក គ្រាន់តែពេលនាងខ្ញុំទទួលនាងខ្ញុំដាក់ឈ្មោះនាងខ្ញុំនៅខាងលើ ក្រោមអង្គកា។

-មេធាវីតំណាងឱ្យប្រជាពលរដ្ឋបានឆ្លើយនាពេលសវនាការថាៈ ក្នុងរឿងនេះ ខ្ញុំជាតំណាងឱ្យប្រជាពលរដ្ឋចំនួន១៣០គ្រួសារ រស់នៅភូមិស្វាយព្រៃ និងភូមិតាំងជ្រៃ ឃុំសណ្តែក ស្រុកបាធាយ ខេត្តកំពង់ចាម សូមប្តឹងទាមទារការខូចខាតពីអង្គការគ្រួសាររ៉ុងរឿងអភិវឌ្ឍន៍កម្ពុជា ដែលមានឈ្មោះ [redacted] ចាន់នី ឈ្មោះ [redacted] វៃ និងឈ្មោះ [redacted] ម៉ាប់ ជាប្រធានអង្គការ និងជាអ្នកទទួលប្រាក់ពីប្រជាពលរដ្ឋ នូវទឹកប្រាក់ចំនួន១.១២០.០៥២.០០០(មួយពាន់ មួយរយម្ភៃលាន ហាសិបពីរពាន់)រៀល ប្រាក់ដុល្លាចំនួន ៦៤៣.៦៧៩ (ប្រាំមួយសែនបួនម៉ឺនបីពាន់ប្រាំមួយរយចិតប្រាំបួន)ដុល្លាអាមេរិក និងជំងឺចិត្តចំនួន២០០.០០០(ម្ភៃម៉ឺន)ដុល្លាអាមេរិក។ ដោយហេតុថា កាលពីទំឡុងឆ្នាំ២០១៤ រហូតដល់ឆ្នាំ២០១៧ ប្រជាពលរដ្ឋទាំង១៣០គ្រួសារបានយកប្រាក់មកដាក់បញ្ញើនៅអង្គការគ្រួសាររ៉ុងរឿងអភិវឌ្ឍន៍កម្ពុជានេះ ដោយមានឈ្មោះ [redacted] វៃ និងឈ្មោះ [redacted] ម៉ាប់ ជាអ្នកទទួល ហើយប្រាក់ទាំងនេះប្រជាពលរដ្ឋមិនបានទទួលប្រាក់ត្រឡប់មកវិញទេ។

## សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ថ្ងៃនេះសាលាដំបូងខេត្តកំពង់ចាម បានលើកយកសំណុំរឿងលេខ៩៩ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៨ ដើម្បីជំនុំជម្រះបន្តកាលពីថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទឈ្មោះ [redacted] ចន្ទនី ហៅ [redacted] ចាន់នី ភេទប្រុស អាយុ២៩ឆ្នាំ ឈ្មោះ [redacted] វៃ ភេទប្រុស អាយុ៥២ឆ្នាំ ដែលមានវត្តមាននៅទីនេះ និងឈ្មោះ [redacted] ម៉ាប់ ភេទស្រី អាយុ២៩ឆ្នាំ ដែលជាកូនរបស់ឈ្មោះ [redacted] ក៏មានវត្តមាននៅទីនេះផងដែរ ដែលបានប្រព្រឹត្តកាលពីអំឡុងឆ្នាំ២០១៤ នៅភូមិស្វាយ ឃុំ..ដែលត្រូវចោទប្រកាន់ពីបទ រំលោភលើទំនុកចិត្ត បានជាតំណាងអយ្យការធ្វើការចោទប្រកាន់បទល្មើសនេះ ដោយផ្អែកទៅលើអង្គហេតុ គឺនៅក្នុងអំឡុងឆ្នាំ២០១៤ ប្រជាពលរដ្ឋពិតជាបានយកលុយទៅដាក់នៅអង្គការគ្រួសាររ៉ុងរឿងអភិវឌ្ឍន៍កម្ពុជា ដើម្បីទទួលបានផលចំណេញ ពីអង្គការនេះ ហើយអង្គការក៏បានបំពេញនូវការងាររបស់ខ្លួន ពោលគឺបានបើកការប្រាក់ឱ្យប្រជាពលរដ្ឋបានមួយរយៈពេល ហើយក្រោយមកក៏មិនបានបើកឱ្យ

Scanned with CamScanner

ប្រជាពលរដ្ឋ ហេតុនេះដោយផ្អែកទៅលើពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ ទើបតំណាងអយ្យការធ្វើការចោទប្រកាន់ទៅលើជនជាប់ចោទ។ តំណាងអយ្យការជឿថា ការចោទប្រកាន់របស់តំណាងអយ្យការពិតជាមានអង្គហេតុគ្រប់គ្រាន់ ដើម្បីធ្វើការចោទប្រកាន់ ជាងនេះទៅទៀត នៅពេលសួរចម្លើយជនជាប់ចោទ គឺជនជាប់ចោទបានឆ្លើយសារភាពថា ខ្លួនពិតបានទទួលលុយពីប្រជាពលរដ្ឋ រួមទាំងបានផ្តល់ឯកសារដល់ប្រជាពលរដ្ឋ ដើម្បីទទួលបានទំនុកចិត្តពីអង្គការគ្រួសាររ៉ុងរឿងនេះផងដែរ។ មួយវិញទៀតខ្លួនក៏មានទំនាក់ទំនងជាមួយមេខ្លោងម្នាក់ទៀតឈ្មោះ [redacted] ចាន់ឌី ដែលបានរត់គេចខ្លួន លើសពីនេះទៅទៀតគឺមានសាក្សីដាក់បន្ទុកទៅលើជនជាប់ចោទ ដែលសាក្សីទាំងនេះត្រូវបានបាត់បង់លុយកាក់ខ្លួនជាច្រើន និងសាក្សីជាជនរងគ្រោះជាច្រើនទៀតដែលមានរហូតទៅដល់១៨៦គ្រួសារ និងតាមអាជ្ញាធរអះអាងបានគឺមានរហូតដល់ទៅជាង២០០គ្រួសារ ។ បន្ថែមពីលើនេះមានភស្តុតាងគ្រប់គ្រាន់គឺម្នាក់ៗបានយកលុយទៅដាក់នៅគ្រួសារអង្គការរ៉ុងរឿង ដែលអង្គការនេះមានរចនាសម្ព័ន្ធគ្រប់គ្រាន់ដែលមានឈ្មោះ[redacted] ចាន់ឌី ជាប្រធាន និងមានអ្នកទទួលចាត់ការដែលទទួលបានប្រាក់ខែ ដែលមានឈ្មោះ [redacted] វៃ ជាមួយឈ្មោះ [redacted] ម៉ាប់ ជាអ្នកទទួលនឹងបញ្ជូន ជាមួយគ្នានេះដែរក៏មានឯកសារដែលបង្ហាញពីឈ្មោះ[redacted] វៃ ដែលមានភាគហ៊ុនដោយផ្ទាល់ជាមួយឈ្មោះ[redacted] ចាន់ឌី។ ហេតុនេះដោយផ្អែកទៅលើអង្គហេតុ ទៅលើសាក្សីដាក់បន្ទុក ទៅលើជនជាប់ចោទ ទៅលើភស្តុតាងដែលមានជាច្រើននៅក្នុងសំណុំរឿង បង្ហាញឱ្យឃើញថា ជនជាប់ចោទពិតជាមានធាតុផ្សំគ្រប់គ្រាន់ធ្វើការចោទប្រកាន់ទាក់ទងជាមួយប្រជាពលរដ្ឋ ហើយមិនបានយកលុយមកឱ្យប្រជាពលរដ្ឋវិញ តាមដែលប្រជាពលរដ្ឋត្រូវការ។ តំណាងអយ្យការសុំតម្កល់ដីកាចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ២៧១ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩ ទុកជាបានការដដែល និងប្តឹងសុំឱ្យចៅក្រមជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទទៅតាមកំណត់ច្បាប់ និងសម្រេចចាប់ និងឃុំខ្លួនជនជាប់ចោទនាពេលនេះតែម្តង។

<u>សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឱ្យប្រជាពលរដ្ឋ</u>

ក្នុងនាមខ្ញុំជាមេធាវីតំណាងឱ្យប្រជាពលរដ្ឋទាំងអស់ រឿងនេះព្យសនកម្មនៃអំពើនេះធំណាស់ មានប្រជាពលរដ្ឋចំនួន១៣២គ្រួសារ ដែលមាននៅក្នុងបញ្ជី អ្នកខ្លះយកប្លង់ដី ប្លង់ផ្ទះ យកលុយពីធនាគារមកដាក់នៅឈ្មោះ [redacted] វៃ យកពីរភាគរយ ឬមួយភាគរយមក យកមកដាក់នៅឈ្មោះ [redacted] វៃ តែបានបាត់ទាំងការ ទាំងដើម ប្រជាពលរដ្ឋប្រឈមមុខនឹងអស់ផ្ទះសំបែង អត់ដីធ្វើស្រែ ហើយប្រជាពលរដ្ឋខ្លះឈ្លោះគ្នាប្តីប្រពន្ធរកលែងគ្នាក៏មានដែរ រឿងយកលុយមកដាក់នឹង អីចឹងព្យសនកម្មនៃអំពើដែលកើតឡើងពីឈ្មោះ [redacted] វៃ ឈ្មោះ [redacted] ម៉ាប់ និងឈ្មោះ [redacted] ចាន់ឌី បានផ្តល់ព្យសនកម្មខ្លាំងណាស់ដល់ប្រជាពលរដ្ឋ ហើយប្រជាពលរដ្ឋមានច្រើនគ្រួសារ។ សូមបញ្ជាក់ផងដែរថា មកដល់ពេលនេះ ឃើញថាឈ្មោះ [redacted] វៃ ដែលមានវត្តមាននៅទីនេះ មានចេតនាឆ្លើយគេចវេសជាច្រើននាពេលសវនាការនេះ ដោយពុំមានស្មារតីភ្ញាក់រលឹក ទទួលខុសត្រូវណាមួយទេ។ ខ្ញុំជឿថា ប្រជាពលរដ្ឋនឹងទទួលបានសំណងរបស់គាត់វិញគ្រប់ចំនួននោះទេ អ្វីដែលជាការឆ្លើយតបរបស់ឈ្មោះ[redacted] វៃ នាពេលសវនាការនេះ មិនអាចឱ្យប្រជាពលរដ្ឋមានសង្ឃឹមថា លុយដែលគាត់ដាក់ទៅ និងបានមកវិញដោយរបៀបណា។ មួយវិញទៀតខ្ញុំសូមឯកភាពទាំងស្រុងនូវអ្វីដែលតំណាងអយ្យការលើកឡើងមានភស្តុងដាក់បន្ទុក មានធាតុផ្សំគ្រប់គ្រាន់ ដែលអាចចោទប្រកាន់លើឈ្មោះ [redacted] វៃ ឈ្មោះ [redacted] ម៉ាប់ និងឈ្មោះ [redacted] ចាន់ឌី ពីបទល្មើស រំលោភលើទំនុក គឺជាអំពើកេងបំបាត់មូលនិធិ ឬ

Scanned with CamScanner

ទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋ ដែលគេបានយកទៅដាក់ខ្លួន ហើយខ្លួនមានកាតព្វកិច្ចប្រគល់ឱ្យទៅប្រជាពលរដ្ឋនូវមូលនិធិ ឬទ្រព្យសម្បត្តិទៅពួកគាត់ដែលបានដាក់ ត្រឡប់មកវិញ អីចឹងបទល្មើសនេះគឺមានធាតុផ្សំគ្រប់គ្រាន់ ហើយសកម្មភាពនេះ គឺមានភាពស៊ីចង្វាក់ខ្លាំងមែនទែនទៅនឹងនិយមន័យដែលច្បាប់បានកំណត់។ ដូច្នេះក្នុងនាមខ្ញុំជាតំណាងឱ្យប្រជាពលរដ្ឋ សូមស្នើសុំឱ្យតុលាការសម្រេចផ្ដល់យុត្តិធម៌ឱ្យប្រជាពលរដ្ឋ តាមការស្នើសុំដែលមាននៅក្នុងបណ្ដឹងនូវប្រាក់ដែលបានខូចខាតចំនួន និងប្រាក់ជំងឺចិត្ត និងស្នើសុំឱ្យចាប់ខ្លួនឈ្មោះ [redacted]វៃ ឈ្មោះ[redacted]ម៉ាប់ នៅពេលនេះតែម្ដង។

<u>សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារឱ្យជនជាប់ចោទ</u>

ក្រោយពីបានពិនិត្យឯកសារពាក់ព័ន្ធក្នុងសំណុំរឿង ក្រោយពីបានស្ដាប់ចម្លើយជនត្រូវចោទនាពេលសវនាការ ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ និងសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារឱ្យប្រជាពលរដ្ឋ។ក្នុងរឿងនេះខ្ញុំសូមធ្វើការសន្និដ្ឋានជាពីរចំណែក ទី១ពាក់ព័ន្ធទៅលើឈ្មោះ [redacted] វៃ តាមអង្គហេតុបានបញ្ជាក់ជូនយ៉ាងច្បាស់ថា ឈ្មោះ [redacted] វៃ ត្រូវបានឈ្មោះ [redacted] ចាន់ឌី មានទំនាក់ទំនងក្នុងការប្រតិបត្តិការណ៍សាច់ប្រាក់ ដើម្បីចងការប្រាក់ ហើយអង្គហេតុនេះបើសង្ខេបមកវិញ តើមានធាតុផ្សំបទល្មើសអ្វីដែលចោទប្រកាន់ឈ្មោះ [redacted] វៃ អំពីបទ រំលោភលើសេចក្ដីទុកចិត្ត យើងពិនិត្យលើកិច្ចសន្យាទទួលប្រាក់បញ្ញើ កិច្ចសន្យា ពាក្យថាកិច្ចសន្យានៅក្នុងក្រមរដ្ឋប្បវេណី កិច្ចសន្យា គឺជាច្បាប់រវាងគូភាគីទាំងពីរ ពាក្យថាកិច្ចសន្យា អ្នកធ្វើកិច្ចសន្យាដើម្បីអ្វី ក្នុងកិច្ចសន្យានេះ គឺដើម្បីចំណេញប្រាក់ សួរថា ពលរដ្ឋដែលអ្នកដាក់ប្រាក់មកនេះ គាត់មានបានទទួលកំរៃចំណេញលើកទី១ លើកទី២ អ្នកខ្លះបានចំណេញមួយដង ឬពីរដងទេ គឺគាត់ទទួលបាន អីចឹងចិត្តគាត់ចង់បានប្រាក់ចំណេញ ទើបគាត់ដាក់ដើមទុន អីចឹងសួរថា នេះជាបទល្មើសរំលោភលើសេចក្ដីទុកចិត្ត ឬយ៉ាងណា តែរឿងក្ដីនេះដោយកូនក្ដីអកុសល្យ គាត់មិនចេះដឹងបានជ្រៅជ្រះ គាត់ឃើញថា ឈ្មោះ [redacted] ចាន់ឌី មានអជ្ញាប័ណ្ណត្រឹមត្រូវដែលបង្កើតអង្គការគ្រូសារវ៉ុងរឿងអភិវឌ្ឍន៍កម្ពុជា គឺគាត់ទុកចិត្ត មានទំនុកចិត្តទៅលើឈ្មោះ [redacted] ចាន់ឌី។ ផ្ទុយទៅវិញគាត់ជាជនរងគ្រោះមួយ ដែលឈ្មោះ [redacted] ចាន់ឌី បោកគាត់ ហើយឈ្មោះ [redacted] ចាន់ឌី នោះបោកគាត់ គឺគេចេះជាងគាត់ ដូចគាត់បាននិយាយចឹង មុនដំបូងគាត់ឃើញថាឈ្មោះ [redacted] ចាន់ឌី មកនិយាយលួងលោមគាត់ ធ្វើឱ្យគាត់លុង។អីចឹងសួរថា លិខិតកិច្ចសន្យាទទួលប្រាក់បញ្ញើនឹង តើវាជាលិខិតព្រមព្រៀងគ្នា ឬជាលិខិតមួយរំលោភលើទំនុកចិត្ត នេះក៏ដោយសារតែប្រជាពលរដ្ឋ ចង់បានចំណេញ ដូចលោកមេធាវីលើកឡើងចឹង ថា អ្នកខ្វះយកប្លង់ដីនៅធនាគារ កូនក្ដីខ្ញុំមិនបានទទួលអ្វីជាថ្នូរនៃការដាក់ទទួលប្រាក់ទេ គឺទទួលជាប្រាក់សុទ្ធ គ្មានអ្វីធានាទេ គាត់ចង់បានចំណេញ គាត់រកស៊ីដោយខ្លួនគាត់ដែរ មិនអាចបន្ទោសទៅលើជនជាប់ចោទទេ ប្រជាពលរដ្ឋ គាត់ចង់បានប្រាក់ចំណេញដែរ។ ដូច្នេះសួរថា តើកូនក្ដីខ្ញុំបានអីពីពួកគាត់ មានទទួលបានប្រាក់ចំណេញទេ មិនមានអ្វីបញ្ជាក់ថាកូនក្ដីខ្ញុំគាត់ទទួលបានចំណេញទេ ប៉ុន្តែរឿងនេះគាត់អកុសលបានចាញ់បោកឈ្មោះ [redacted] ចាន់ឌី។ ក្នុងអង្គហេតុនេះ ខ្ញុំបាទសូមលោកចៅក្រមពិចារណាទៅលើឈ្មោះ [redacted] វៃ ថាតើមានធាតុផ្សំបទល្មើសព្រហ្មទណ្ឌបទរំលោភលើទំនុកចិត្តឬយ៉ាងណា មួយទៀតចំពោះការស្នើសុំចាប់ខ្លួន ឈ្មោះ [redacted] វៃត្រូវបានតុលាការកោះហៅគ្រប់នីតិវិធីនៅចំពោះមុខតំណាងអយ្យការ នៅចំពោះមុខចៅក្រមស៊ើបសួរនៅចំពោះមុខអង្គសវការ តើមានហេតុផលណាគួរចាប់ខ្លួនគាត់នៅពេលនេះ ដើម្បីអ្វី។ យើង

Scanned with CamScanner

ត្រូវរកឫសគល់នៃបទល្មើស ថាតើផ្តើមចេញពីនរណា គឺផ្តើមចេញពីឈ្មោះ [redacted] ចាន់ឌី។ ដូច្នេះខ្ញុំសុំលោកចៅក្រមបដិសេធការស្នើសុំចាប់ខ្លួនឈ្មោះ [redacted] វៃ នៅពេលនោះ។ ទី២ ចំពោះឈ្មោះ [redacted] ម៉ាប់ កាលពីឪពុកធ្វើកិច្ចសន្យាទទួលប្រាក់បញ្ញើ គាត់រស់នៅក្នុងនាមកូន និងឪពុក ធម្មតាកូននៅពេលឪពុកមិននៅ ឬនៅក៏ដោយ ការប្រើជំនួសដៃជើង មិនចាត់ទុកថាកូននឹងបានចូលរួមប្រព្រឹត្តបទល្មើសជាមួយនឹងឪពុកទេ សួរថាឈ្មោះ [redacted] ម៉ាប់ បានចំណេញអីការជួយឪពុកនឹងទេ គឺអត់មានទេ បើយើងចាត់ទុកថាជាបទរំលោភលើទំនុកចិត្ត ដរាបណាឈ្មោះ [redacted] ម៉ាប់ បានចំណេញ បានកេងចំណេញការទទួលប្រាក់បញ្ញើនេះ ទើបចាត់ទុកថាមានបទល្មើសព្រហ្មទណ្ឌ។ ដូច្នេះសុំឱ្យលោកចៅក្រមពិចារណាទៅលើឈ្មោះ [redacted] ម៉ាប់ គប្បីឱ្យផុតពីបទចោទប្រកាន់។

<u>សំដីចុងក្រោយ</u>

-ជនជាប់ចោទឈ្មោះ [redacted] វៃ បានសំណូមពរថាៈ ខ្លួនសុំឲ្យតុលាការលើកលែងខ្លួនឱ្យរួចផុតពីបទចោទ។

-ជនជាប់ចោទឈ្មោះ [redacted] ម៉ាប់ បានសំណូមពរថាៈ ខ្លួនសុំឲ្យតុលាការលើកលែងខ្លួនឱ្យរួចផុតពីបទចោទ។

សាលាដំបូងខេត្តកំពង់ចាម

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
ក្រោយពីបានស្តាប់ចម្លើយរបស់មេធាវីតំណាងឱ្យប្រជាពលរដ្ឋ
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី
ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ
ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

-យល់ឃើញថាៈ ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ ចម្លើយរបស់តំណាងឱ្យប្រជាពលរដ្ឋ សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ សេចក្តីសន្និដ្ឋានរបស់មេធាវី និងការពិនិត្យឯកសារក្នុងសំណុំរឿង ឃើញថា កាលពីអំឡុងឆ្នាំ២០១៤ ស្ថិតនៅភូមិស្វាយព្រៃ ឃុំសណ្តែក ស្រុកបាធាយ ខេត្តកំពង់ចាម មានឈ្មោះ [redacted] ចន្ទឌី ហៅ [redacted] ចាន់ឌី ភេទប្រុស អាយុ ២៩ឆ្នាំ បានបើកអង្គការគ្រួសាររ៉ុងរឿងអភិវឌ្ឍន៍កម្ពុជា ទទួលប្រាក់បញ្ញើ និងផ្តល់ការប្រាក់ ៣% ដល់ប្រជាពលរដ្ឋចំនួន១៣០គ្រួសារ ដែលរស់នៅភូមិ ឃុំខាងលើ ដោយមានឈ្មោះ [redacted] វៃ ភេទប្រុស អាយុ៥១ឆ្នាំ និងឈ្មោះ [redacted] ម៉ាប់ ភេទស្រី អាយុ២៩ឆ្នាំ ជាអ្នកប្រមូលប្រាក់បញ្ញើពីប្រជាពលរដ្ឋឱ្យទៅអង្គការគ្រួសាររ៉ុងរឿងអភិវឌ្ឍន៍កម្ពុជា និងមិនបានប្រគល់ប្រាក់ឱ្យប្រជាពលរដ្ឋវិញ ពិតប្រាកដមែន។

-យល់ឃើញថាៈ ជនជាប់ចោទឈ្មោះ [redacted] វៃ និងឈ្មោះ [redacted] ម៉ាប់ ទទួលប្រាក់ពីប្រជាពលរដ្ឋចំនួន១៣០គ្រួសារ ហើយមិនបានប្រគល់ឱ្យប្រជាពលរដ្ឋវិញប្រាកដមែន។

-យល់ឃើញថាៈ ជនជាប់ចោទឈ្មោះ [redacted] ចាន់ឌី ពិតជាបានទទួលប្រាក់បន្តពីជនជាប់ចោទឈ្មោះ [redacted] វៃ និងឈ្មោះ [redacted] ម៉ាប់ ហើយបានរត់គេចខ្លួន ពុំចូលខ្លួនមកសវនាការនៅតុលាការឡើយ។

Scanned with CamScanner

-យល់ឃើញថា៖ អំពើ និងសកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់ឌី ឈ្មោះ [redacted] ន វៃ និងឈ្មោះ [redacted] ម៉ាប់ បានតែបំបាត់មូលនិធិធ្វើឱ្យខូចប្រយោជន៍អ្នកដទៃ ជាអំពើប្រព្រឹត្ត ផ្ទុយនឹងមាត្រា៣៩១ មាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ។

-យល់ឃើញថា៖ ជនជាប់ចោទពិតជាមានស្មារតីគ្រប់គ្រាន់ នៅពេលប្រព្រឹត្តបទល្មើស ដែលធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម។

-យល់ឃើញថា៖ គ្មានភស្តុតាងណាបញ្ជាក់ថាជនជាប់ចោទ ជាជនវិកលចរិក ឬវិបល្លាសស្មារតីឡើយ ផ្ទុយទៅវិញជនជាប់ចោទជាបុគ្គលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ។

-យល់ឃើញថា៖ មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ចន្ទឌី ហៅ [redacted] ចាន់ឌី ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ ឈ្មោះ [redacted] វៃ ភេទប្រុស អាយុ៥២ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] ម៉ាប់ ភេទស្រី អាយុ២៩ឆ្នាំ ជាតិខ្មែរ (ដែលមានសាវតាជាតិដូចខាងលើ)។

ពីបទ: *រំលោភលើទំនុកចិត្ត* ប្រព្រឹត្តនៅភូមិស្វាយព្រៃ ឃុំសណ្តែក ស្រុកបាធាយ ខេត្តកំពង់ចាម កាលពីអំឡុងឆ្នាំ២០១៨បទល្មើសដែលមានចែង និងផ្តន្ទាទោស តាមមាត្រា ៣៩១ មាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ។

-យល់ឃើញថា៖ ការតម្កល់បទចោទរបស់តំណាងអយ្យការ តាមដីកាសន្និដ្ឋានរបស់ខ្លួន និងការស្នើសុំឱ្យចាប់ ឃុំខ្លួនជនជាប់ចោទ ក្នុងពេលសវនាការនេះ គប្បីតុលាការពិចារណាសម្រេច។

-យល់ឃើញថា៖ ការស្នើសុំរបស់មេធាវីតំណាងឱ្យប្រជាពលរដ្ឋ ក្នុងពេលសវនាការទាមទារការខូចខាតនូវទឹកប្រាក់ចំនួន១.១២០.០៥២.០០០(មួយពាន់មួយរយម្ភៃលានហាសិបពីរពាន់)រៀល និងប្រាក់ដុល្លាចំនួន ៦៤៣.៦៧៩ (ប្រាំមួយសែនបួនម៉ឺនបីពាន់ប្រាំមួយរយចិតប្រាំបួន)ដុល្លាអាមេរិក និងជំងឺចិត្តចំនួន២០០.០០០(ម្ភៃម៉ឺន)ដុល្លាអាមេរិក។ គប្បីតុលាការពិចារណាតាមការជាក់ស្តែង។

-យល់ឃើញថា៖ ការស្នើសុំរបស់មេធាវីការពារឱ្យជនជាប់ចោទ ក្នុងពេលសវនាការដែលបានសន្និដ្ឋានស្នើសុំឱ្យជនជាប់ចោទរួចផុតពីបទចោទ តុលាការពុំលើកយកមកពិចារណាសម្រេចឡើយ។

-យល់ឃើញថា៖ ការសំណូមពររបស់ជនជាប់ចោទ ស្នើសុំឱ្យរួចផុតពីបទចោទ តុលាការពុំលើកយកមកពិចារណាសម្រេចឡើយ។

<u>ហេតុដូច្នេះ</u>

<u>វិនិច្ឆ័យសេចក្តី</u>

១/ផ្តន្ទាទោសជនជាប់ចោទ៖

ក.ឈ្មោះ [redacted] *ចន្ទឌី ហៅចន ចាន់ឌី* ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ០៣ (បី) ឆ្នាំ។

ខ.ឈ្មោះ [redacted] *វៃ* ភេទប្រុស អាយុ៥២ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] *ម៉ាប់* ភេទស្រី អាយុ២៩ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ចំនួន ០២ (ពីរ) ឆ្នាំ។

ពីបទ *រំលោភលើទំនុកចិត្ត* ប្រព្រឹត្តនៅភូមិស្វាយព្រៃ ឃុំសណ្តែក ស្រុកបាធាយ ខេត្តកំពង់ចាម កាលអំឡុងឆ្នាំ២០១៨ តាមមាត្រា ៣៩១ មាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ។

Scanned with CamScanner

-ចេញដីកាបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] *ចន្ទឌី ហៅ* [redacted] *ចាន់ឌី* និងបង្គាប់ឱ្យឃុំខ្លួនឈ្មោះ [redacted] *វ៉*ណ្ណាម តាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២/ បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] *ចន្ទីឌី ហៅ* [redacted] *ចាន់ឌី* ឈ្មោះ [redacted] *វ៉* និងឈ្មោះ [redacted] *ម៉ាប់* រួបរួមគ្នាសងសំណងការខូចខាតចំនួន១.១២០.០៥២.០០០(មួយពាន់មួយរយម្ភៃលានហាសិបពីរពាន់)រៀល និងប្រាក់ដុល្លាចំនួន ៦៤៣.៦៧៩ (ប្រាំមួយសែនបួនម៉ឺនបីពាន់ប្រាំមួយរយចិតប្រាំបួន)ដុល្លាអាមេរិក ឱ្យទៅតាមចំណែកនៃប្រាក់ខូចខាតរបស់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗ និងជម្ងឺចិត្តប្រាក់រៀលស្មើនឹងប្រាក់ដុល្លាអាមេរិកចំនួន១០០.០០០(ដប់ម៉ឺន)ដុល្លា។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] *វ៉* និងឈ្មោះ [redacted] *ម៉ាប់* កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] *ចន្ទីឌី ហៅ* [redacted] *ចាន់ឌី* ។ បើភាគីណាមិនសុខចិត្តនឹងសេចក្តីសម្រេចនេះ មានសិទ្ធិប្តឹងទាស់ , ប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ក្រឡាបញ្ជីសវនាការ
ហត្ថលេខា និងត្រា [redacted]

ចៅក្រមជំនុំជម្រះ
ហត្ថលេខា និងត្រា [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃសុក្រ០១កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
កំពង់ចាម,ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩
ក្រឡាបញ្ជី

[redacted]

បានឃើញ
ចៅក្រមជំនុំជម្រះ

[redacted]

Scanned with CamScanner